ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈ នៃការយោគយល់

## រវាង

## ក្រសួងមហាផ្ទៃ

## និង

## អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia)

## ស្ដីពី

## ការចូលរួមសកម្មភាពមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា

២០២៤- ២០២៩

# បុព្វកថា

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) ដែលតទៅនេះកំណត់ថា "គូភាគី"

ដោយហេតុថា ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា បានសំដែងនូវបំណងប្រាថ្នាដូចដែលមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់នេះថា អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) បានរួមចំណែកធ្វើការងារមនុស្សធម៌ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈ តាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ដោយហេតុថា អង្គការសកម្មភាពដើម្បីកុមារ និងក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សហការគ្នាប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារព្រមទាំងទម្រង់ផ្សេងទៀតនៃអំពើជួញដូរមនុស្ស

ដោយហេតុថា ដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ អង្គការសកម្មភាពដើម្បីកុមារ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) តាមរយៈការសហការផ្ទាល់ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ និងជាពិសេសជាមួយនាយកដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ មានឆន្ទៈ និងប្តេជ្ញាបន្តកិច្ចសហការលើសកម្មភាព និងកម្មវិធីមនុស្សធម៌

ដោយគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជា

គូភាគីបានព្រមព្រៀងឯកភាពគ្នាដូចតទៅ៖

## ប្រការ១

## គោលបំណង

គូភាគីត្រូវពង្រឹងកិច្ចសហការក្នុងការបង្ការ បង្ក្រាប សង្គ្រោះ ការពារ និងផ្តន្ទាទោសអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារគ្រប់ទម្រង់ និងពង្រឹងសមត្ថភាពស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ។

## ប្រការ២

## ភារកិច្ចរបស់ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ មានភារកិច្ចដូចខាងក្រោម៖

- ទទួលស្គាល់ភាពស្របច្បាប់នៃការប្រមូល និងផ្តល់ព័ត៌មាន ឬភស្តុតាង ឬតម្រុយពាក់ព័ន្ធករណីសង្ស័យនៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ទៅអគ្គស្នងការដ្ឋាននគរបាលជាតិ ឬអាជ្ញាធរមានសមត្ថកិច្ច ដែលអង្គការសកម្មភាពដើម្បីកុមារអនុវត្ត ក្នុងគោលបំណងចូលរួមបង្ការ ទប់ស្កាត់ និងកំណត់អត្តសញ្ញាណសង្គ្រោះជនរងគ្រោះ។

- សហការ និងសម្របសម្រួលជាមួយ អង្គការសកម្មភាពដើម្បីកុមារ ក្នុងការរៀបចំការបណ្ដុះបណ្ដាល និងការពង្រឹងសមត្ថភាពលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ ដល់មន្ត្រីរដ្ឋាភិបាល នគរបាលជំនាញ អាជ្ញាធរមានសមត្ថកិច្ច អ្នកធ្វើការជួរមុខ និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន។
- តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ឬគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) សហការ និងសម្របសម្រួលជាមួយ អង្គការសកម្មភាពដើម្បីកុមារ ក្នុងការរៀបចំការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីការបង្ការទប់ស្កាត់ និងឆ្លើយតបអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ ដល់ សមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អាជ្ញាធរ សហគមន៍ អង្គការដៃគូ អាណាព្យាបាល យុវជន កុមារ និងផ្នែកឯកជន។
- តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សហការ និងសម្របសម្រួលជាមួយអង្គការសកម្មភាពដើម្បីកុមារ ធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ និងចងក្រងរបាយការណ៍អំពីរបកគំហើញ និងអនុសាសន៍ ដើម្បីប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តផែនការសកម្មភាព អប់រំផ្សព្វផ្សាយ និងតស៊ូមតិ សំដៅលើកកម្ពស់ការយល់ដឹង និងជំរុញការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារជាជនរងគ្រោះ។

## ប្រការ៣

## ភារកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ

អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំការស៊ើបអង្កេត ប្រមូលភស្តុតាង កំណត់អត្តសញ្ញាណជនរងគ្រោះ សង្គ្រោះ និងការពារជនរងគ្រោះ និងចាត់វិធានការតាមផ្លូវច្បាប់លើករណីពាក់ព័ន្ធអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ ដែលអង្គការសកម្មភាពដើម្បីកុមារបានបញ្ជូនទៅ។
- ទទួលស្គាល់នូវប្រតិបត្តិការបណ្ដាញរាយការណ៍បន្ទាន់តាមទូរស័ព្ទ និងអ៊ីនធឺណិតរបស់អង្គការសកម្មភាពដើម្បីកុមារ និងការប្រើប្រាស់ឧបករណ៍បច្ចេកទេសទាំងឡាយ ដើម្បីពិនិត្យ វិភាគ និងវាយតម្លៃព័ត៌មានពាក់ព័ន្ធនឹងករណីកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ និងមាតិកាទាក់ទងនឹងរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ មុននឹងបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬស្ថាប័នអយ្យការ។

## ប្រការ៤

## ភារកិច្ចរួមរបស់អគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជានៃក្រសួងមហាផ្ទៃ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ មានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ ដើម្បីផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ក្នុងគោលបំណងបង្ការទប់ស្កាត់ សង្គ្រោះជនរងគ្រោះ បង្ក្រាបបទល្មើស និងកសាងសំណុំរឿងតាមនីតិវិធីច្បាប់។
- ផ្តល់កិច្ចសហការក្នុងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ការប៉ាន់ប្រមាណតម្រូវការបឋម សម្របសម្រួលឱ្យមានការពិនិត្យកោសល្យវិច័យវេជ្ជសាស្ត្រ និងលើកកម្ពស់ការចូលរួមរបស់អាណាព្យាបាល ឬបុគ្គលិកសង្គមកិច្ច ក្នុងពេលសម្ភាសកុមាររងគ្រោះពីអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ និងបញ្ជូនជនរងគ្រោះបន្តទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ផ្តល់កិច្ចសហការ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងៗទៀតតាមការឯកភាពលើគោលបំណង តម្រូវការ ទីកន្លែង និងរយៈពេលនៃវគ្គបណ្តុះបណ្តាល។
- សហការ និងសម្របសម្រួលក្នុងការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល ព្រមទាំងរៀបចំ ខ្លឹមសារមេរៀន និងសម្ភារៈបណ្តុះបណ្តាលឱ្យសមស្របទៅតាមតម្រូវការ និងការវិវឌ្ឍថ្មីៗនៃស្ថានភាពដែលកើតមានឡើង។
- ផ្តល់អន្តរាគមន៍ជាបន្ទាន់នៅពេលដែលបុគ្គលិកអង្គការសកម្មភាពដើម្បីកុមារ ត្រូវការនូវកិច្ចការពារសុវត្ថិភាព និងសន្តិសុខ។

## ប្រការ៥

## ភារកិច្ចរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia)

អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) មានភារកិច្ចដូចខាងក្រោម៖

- ប្រមូលព័ត៌មាន និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះពាក់ព័ន្ធករណីសង្ស័យនៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ និងផ្តល់ព័ត៌មាន ឬភស្តុតាង ឬតម្រុយជូនអគ្គស្នងការដ្ឋាន នគរបាលជាតិ ឬអាជ្ញាធរមានសមត្ថកិច្ច រួមទាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងការិយាល័យពាក់ព័ន្ធរាជធានីខេត្ត ដើម្បីស៊ើបអង្កេត និងចាត់វិធានការតាមផ្លូវច្បាប់។
- ធ្វើប្រតិបត្តិការប្រព័ន្ធរាយការណ៍ពិសេសតាមទូរស័ព្ទ២៤ម៉ោង (០៩២ ៣១១ ៥១១) និងបណ្តាញរាយការណ៍បន្ទាន់តាមអ៊ីនធឺណិត (Internet Hotline) ដើម្បីទទួលការរាយការណ៍អំពីករណីសង្ស័យពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ និងរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ឬរូបភាព-សម្ភារៈអាសអាភាសកុមារនៅលើប្រព័ន្ធអនឡាញ ក្នុងគោលបំណងបង្ការ ទប់ស្កាត់ និងឆ្លើយតបទៅនឹងករណីទាំងនេះប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។
- ធ្វើការពិនិត្យ និងវាយតម្លៃមាតិកាពាក់ព័ន្ធនឹងរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ឬរូបភាព-សម្ភារៈអាសអាភាសកុមារ និងបញ្ជូនព័ត៌មាន ឬរបាយការណ៍ទៅអគ្គស្នងការដ្ឋាននគរបាលជាតិ ឬ

អាជ្ញាធរមានសមត្ថកិច្ច បណ្តាញរាយការណ៍បន្ទាន់តាមអ៊ីនធឺណិតនៃមូលនិធិសកលអ៊ីនហូប (INHOPE) និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ដើម្បីស្នើសុំដកហូតមាតិកាខុសច្បាប់ចេញ និងកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ។

- សហការ សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេសដល់អគ្គស្នងការដ្ឋាននគរបាលជាតិ ជាពិសេសនាយកដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ ដើម្បីជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ និងសង្គ្រោះជនរងគ្រោះ។
- សហការ និងសម្របសម្រួលដល់ការទទួលបានសេវាសមស្រប ដូចជាការប្រឹក្សាយោបល់ សេវាសង្គម ការថែទាំសុខភាព ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងជំនួយផ្លូវច្បាប់សម្រាប់ជនរងគ្រោះ និងគ្រួសារ។
- រៀបចំ និងសម្របសម្រួលឱ្យមានកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងស្វែងរកកត្តាប្រឈម ចន្លោះប្រហោង ឧត្តមានុវត្ត និងដំណោះស្រាយ ដើម្បីជំរុញស័ក្តិសិទ្ធិភាព ចីរភាព និងបរិយាបន្ននៃការអនុវត្តយុទ្ធសាស្ត្រ ឬផែនការសកម្មភាពជាតិ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ។
- រៀបចំ និងសម្របសម្រួលឱ្យមានកិច្ចប្រជុំផ្លាស់ប្តូរយោបល់ និងបទពិសោធន៍រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានជំនាញពាក់ព័ន្ធ និងនគរបាលអន្តរជាតិលើការស៊ើបអង្កេត និងឆ្លើយតបករណីជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ។
- ដឹកនាំ រៀបចំ និងសម្របសម្រួលការបណ្តុះបណ្តាល ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីនគរបាលជាគ្រូបង្គោល ជាពិសេសពីនាយកដ្ឋាន និងការិយាល័យជំនាញលើការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ និងការឆ្លើយតបបែបកុមារមេត្រីលើករណីជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ។
- ដឹកនាំ រៀបចំ និងសម្របសម្រួលការពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញប្រឆាំងការជួញដូរមនុស្ស អ្នកធ្វើការជួរមុខ និងអាជ្ញាធរទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន ។
- រៀបចំ និងសម្របសម្រួលឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងសិក្ខាសាលាពិគ្រោះយោបល់ កិច្ចប្រជុំពិភាក្សា ការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនកិច្ចសិក្សា ទាំងក្នុងនិងក្រៅប្រទេសសំដៅពង្រឹងចំណេះដឹង និងជំនាញលើកិច្ចការពារកុមារពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ។
- សហការ និងសម្របសម្រួលការអនុវត្ត តាមដាន និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់នគរបាលជាតិ និងប្រមូលផលគម្រោងសម្រាប់ធ្វើរបាយការណ៍ និងផែនការបន្ត។
- សហការ និងសម្របសម្រួលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងនាយកដ្ឋានពាក់ព័ន្ធក្នុងការផ្សព្វផ្សាយ ជំរុញ និងលើកកម្ពស់ការអនុវត្តបែបកុមារមេត្រីរបស់នគរបាលជាតិក្នុងដំណើរការស៊ើបអង្កេតករណីកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ។

- រៀបចំ និងសម្របសម្រួលជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្នុងការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីការបង្ការ ទប់ស្កាត់ និងឆ្លើយតបអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារដល់សមាជិកគណៈកម្មាធិការជាតិ គ.ជ.ប.ជ អាជ្ញាធរពាក់ព័ន្ធ សហគមន៍ អង្គការដៃគូ អាណាព្យាបាល យុវជន កុមារ និងផ្នែកឯកជន។
- សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្ថាប័នពាក់ព័ន្ធ ធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ និងចងក្រងរបាយការណ៍អំពីរបកគំហើញ និងអនុសាសន៍សម្រាប់ប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តផែនការសកម្មភាព ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល និងតស៊ូមតិ សំដៅលើកកម្ពស់ការយល់ដឹងឱ្យបានស៊ីជម្រៅ និងជំរុញការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារជាជនរងគ្រោះ។
- សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អគ្គស្នងការដ្ឋាននគរបាលជាតិ ឬអាជ្ញាធរពាក់ព័ន្ធដើម្បីធ្វើការសិក្សាស្រាវជ្រាវរួមគ្នា និងផ្សព្វផ្សាយលើប្រធានបទដែលភាគីទាំងពីរយល់ស្របគ្នា។
- សហការ និងចូលរួមធ្វើផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារដើម្បីអនុវត្ត។
- សហការ គាំទ្រ និងចូលរួមរៀបចំយុទ្ធនាការថ្នាក់ជាតិ ដូចជាទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត សំដៅលើកកម្ពស់ការយល់ដឹង និងជំរុញការបង្ការ ទប់ស្កាត់ និងឆ្លើយតបអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ។
- ចូលរួម និងផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ និងរបាយការណ៍ស្ថានភាពពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ។
- ធ្វើការបដិសេធការស្នើសុំទាំងឡាយណា ប្រសិនបើការស្នើសុំនោះមានលក្ខណៈផ្ទុយពីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងខ្លឹមសារនៃអនុស្សរណៈយោគយល់នេះ។
- អាចបដិសេធនូវការស្នើសុំទាំងឡាយណា ប្រសិនបើការស្នើសុំនោះមានលក្ខណៈផ្ទុយពីទស្សនៈវិស័យបេសកកម្ម លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង គោលការណ៍ផ្ទៃក្នុងផ្សេងៗរបស់អង្គការសកម្មភាពដើម្បីកុមារ ឬប្រសិនបើការស្នើសុំនោះលើសពីធនធានរបស់អង្គការសកម្មភាពដើម្បីកុមារ។ ក្នុងករណីការស្នើសុំនោះត្រូវបានបដិសេធ អង្គការសកម្មភាពដើម្បីកុមារជូនដំណឹងអំពីព័ត៌មាន និងមូលហេតុនៃការបដិសេធនោះ។
- ផ្តល់ព័ត៌មាន របាយការណ៍អំពីសកម្មភាព និងលទ្ធផលដែលអនុវត្តប្រចាំ(ត្រីមាស និងឆ្នាំ) តាមកាលកំណត់ មកក្រសួងមហាផ្ទៃ និងទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- គម្រោងសង្ខេប របស់អង្គការសកម្មភាពដើម្បីកុមារ ដូចមានជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

## ប្រការ៦

## ភារកិច្ចទទួលខុសត្រូវរបស់អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia)

អង្គការសកម្មភាពដើម្បីកុមារ ត្រូវទទួលខុសត្រូវលើចំណុចដូចខាងក្រោម៖

- គោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនត្រូវអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួន ចូលរួមនូវរាល់សកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជាឡើយ។
- ប្រតិបត្តិនូវរាល់សកម្មភាព និងអនុវត្តនូវកម្មវិធីមនុស្សធម៌នៅក្នុងប្រទេសកម្ពុជាដោយផ្អែកទៅតាមធនធានមនុស្ស និងដែនកំណត់នៃមូលនិធិរបស់ខ្លួន។ ត្រូវធានាថារាល់ព័ត៌មាន និងភស្តុតាងដែលប្រមូលបានត្រូវបញ្ជូនទៅអគ្គស្នងការដ្ឋាននគរបាលជាតិតាមរយៈនាយកដ្ឋាននិងការិយាល័យជំនាញសម្រាប់ចាត់វិធានការតាមផ្លូវច្បាប់បន្ត។
- ប្រកាន់ជំហរអព្យាក្រឹតមិនលម្អៀង និងចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ដែលបានទទួលការអនុញ្ញាតពីក្រសួងមហាផ្ទៃ ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ។
- រក្សាការសម្ងាត់នូវព័ត៌មានដែលទទួលបានក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះ ដោយផ្អែកទៅតាមច្បាប់ជាតិ។ អង្គការសកម្មភាពដើម្បីកុមារ ត្រូវធានាដល់ការការពារចំពោះព័ត៌មានសម្ងាត់ពីការចូលមើល ការស្តាប់ ការកែប្រែ ការបោះពុម្ពផ្សាយ ឬការចែកចាយ ដែលមិនមានការអនុញ្ញាតដោយយោងទៅតាមច្បាប់ជាតិ។

## ប្រការ៧

## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពីការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់នេះ នឹងត្រូវ ដោះស្រាយតាមរយៈការចរចាដោយសន្តិវិធី និងប្រឹក្សាដោយការយោគយល់រវាង ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសកម្មភាពដើម្បីកុមារ។

## ប្រការ៨

## ការធ្វើវិសោធនកម្ម

កិច្ចព្រមព្រៀងនេះនឹងអាចត្រូវបានត្រួតពិនិត្យ ឬធ្វើវិសោធនកម្មឡើងវិញគ្រប់ពេលដោយមានការយល់ព្រមពីគូភាគីជាលាយលក្ខណ៍អក្សរ។

## ប្រការ៩

## ការចូលជាធរមាន និងការបញ្ចប់

អនុស្សរណៈនៃការយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អនុស្សរណៈនៃការយោគយល់នេះ មានសុពលភាពរយៈពេលចំនួន ០៥(ប្រាំ)ឆ្នាំ នឹងអាចបន្តជាថ្មីបានក្នុងករណីមានការឯកភាពគ្នារវាងគូភាគី។

អនុស្សរណៈនៃការយោគយល់នេះអាចត្រូវបញ្ចប់ដោយភាគីណាមួយក៏បាន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីបំណងនៃការបញ្ចប់ការអនុវត្តអនុស្សរណៈជូនភាគីម្ខាងទៀត។ ក្នុងករណីនេះ ការអនុវត្តអនុស្សរណៈនេះ ត្រូវបញ្ចប់ក្រោយរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីបំណងនៃការបញ្ចប់ការអនុវត្តអនុស្សរណៈតទៅ។

## ប្រការ១០

## អវសានប្បញ្ញត្តិ

អនុស្សរណៈនៃការយោគយល់នេះពុំមែនជាកិច្ចព្រមព្រៀង និងពុំបង្កើតសិទ្ធិ និងកាតព្វកិច្ចណាមួយឡើយ។

ចុះហត្ថលេខានៅ.............. ថ្ងៃ៣០ ខែកញ្ញា ឆ្នាំ២០២៤ ជា០២ (ពីរ) ច្បាប់ដើមជាភាសាខ្មែរ។

**តំណាងក្រសួងមហាផ្ទៃ**
**នៃព្រះរាជាណាចក្រកម្ពុជា**

**លោកជំទាវ ជូ ប៊ុនអេង**
**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

**អង្គការសកម្មភាពដើម្បីកុមារ**
**នាយកប្រតិបត្តិ**

**សំលៀង សីលា**

## ឧបសម្ព័ន្ធ

## សង្ខេបគម្រោង

| | | |
|---|---|---|
| **ឈ្មោះអង្គការ** | ៖ | អង្គការសកម្មភាពដើម្បីកុមារ (APLE Cambodia) |
| **ប្រភេទអង្គការ** | ៖ | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| **អាសយដ្ឋាន** | ៖ | ផ្ទះលេខ២៣០៣ ជាន់ទី២៣ អគារហ្វ៊ូធូនថោវវើ ផ្លូវលេខ ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ |
| **លេខទូរសព្ទទំនាក់ទំនង** | ៖ | ០២៣ ៩៩៦ ៣៥១/០១២ ៥៨៤ ១៩៤ |
| **អ៊ីម៉ែល** | ៖ | info@aplecambodia.org; director@aplecambodia.org |
| **ឈ្មោះគម្រោងសកម្មភាព** | ៖ | ពង្រឹងយន្តការសង្គម និងច្បាប់ដើម្បីការពារកុមាររងគ្រោះឬរងការប៉ះពាល់ដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ |
| **លេខកូដគម្រោង** | ៖ | គ្មាន |
| **ទីតាំងគម្រោង** | ៖ | ២៥ រាជធានី ខេត្ត |
| **ថវិកាអនុវត្តគម្រោង** | ៖ | ២,២៥០,០០០ ដុល្លារអាមេរិក |
| **កាលបរិច្ឆេទចាប់ផ្តើម** | ៖ | ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ |
| **កាលបរិច្ឆេទបញ្ចប់** | ៖ | ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៩ |
| **ចំនួនបុគ្គលិកខ្មែរ** | ៖ | ១៥នាក់ |
| **ចំនួនបុគ្គលិកបរទេស** | ៖ | គ្មាន |
| **អ្នកគ្រប់គ្រងគម្រោង** | ៖ | លោក សំលៀង សីលា |